ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ
សាលក្រមព្រហ្មទណ្ឌ
លេខ ៖ ០៧ (ឧ)
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧១៨
ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦

| ពន្ធនាគារខេត្តបន្ទាយមានជ័យ | |
|---|---|
| ទទួល | លេខ: ៣៥៧ |
| | ម៉ោង: ១៥.៣០នាទី |
| | ថ្ងៃទី: ១៦.០២.១៨ |

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ។
កាលបរិច្ឆេទបើកសវនាការ៖ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧
កាលបរិច្ឆេទប្រកាសសាលក្រម៖ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈ ចៅក្រមប្រឹក្សា
លោក [redacted] ឋានៈ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ឋានៈ ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជីសាលាដំបូងខេត្ត

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ**

លោក [redacted]ហុកសេង ឋានៈ ជាមេធាវី
លោក [redacted]ស៊ីដេវីត ឋានៈ ជាមេធាវី
លោក [redacted]សុមុន្នី ឋានៈ ជាមេធាវី
លោក [redacted]ម៉ូលីកា ឋានៈ ជាមេធាវី
លោក [redacted]នី ឋានៈ ជាមេធាវី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧១៨ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ សិស្ស ទីកន្លែងកំណើតភូមិសាច់ប៉ូយ ឃុំវត្តគរ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ស្នាក់នៅបច្ចុប្បន្ន [redacted] ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted]ស ទោសពីមុន គ្មាន ជាទីតិជន។(ក្នុងឃុំ)

**ត្រូវបានចោទពីបទ** ៖ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃ ១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ ចំណុច១ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ឈ្មោះ [redacted]រ៉ូហ្សា ហៅ ស៊ីណា ហៅ មុំ ភេទស្រី អាយុ៤៤ឆ្នាំ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្នមិនពិតប្រាកដ ប្តីឈ្មោះ [redacted](លែងលះ) ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]ស" ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ០៤ខែ ពីបទ រំលោភលើសេចក្តីទុកចិត្ត ជានីតិជន។ (ក្នុងឃុំ)

**ត្រូវបានចោទពីបទ** ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. ឈ្មោះ[redacted] នាង (ឈ្មួន វណ្ណដា) ភេទប្រុស អាយុ៥០ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរម៉ៅការសំណង់ ទីកន្លែងកំណើតភូមិអូរបេង ឃុំអូរបេង ស្រុកប៉ៃលិន ខេត្តបាត់ដំបង ទីលំនៅបច្ចុប្ប[redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ[redacted]"រ" ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ២៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជានីតិជន។(ក្នុងឃុំ)

៤. ឈ្មោះ [redacted] មន្នី ហៅ ថែនី ភេទស្រី អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ ទីកន្លែងកំណើតភូមិកោះរកាក្នុង ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅបច្ចុ [redacted] ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្តីឈ្មោះ [redacted] ហៅ ដា ឪពុកឈ្មោះ [redacted]"រ" ម្តាយឈ្មោះ [redacted]"រ" ទោសពីមុនគ្មាន ជានីតិជន។ (ក្នុងឃុំ).

៥. ឈ្មោះ[redacted]បីហៀង ហៅ ហៀង ភេទប្រុស អាយុ៣៤ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិអូរចំលង ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ទីលំនៅបច្ចុប្ប[redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ[redacted]លែងលះ) ឪពុកឈ្មោះ [redacted]ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ២៥ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជានីតិជន។(ក្នុងឃុំ)

៦. ឈ្មោះ [redacted]សារី ហៅ ពាក់ ភេទប្រុស កើតឆ្នាំ១៩៨០ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតភូមិសែនពន្ទក ឃុំសំពោង ស្រុកទូកមាស ខេត្តកំពត ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] (លែងលះ) ឪពុកឈ្មោះ [redacted]



Scanned with CamScanner

·ស· ម្ដាយឈ្មោះ [redacted] ទោសពីមុន ធ្លាប់ជប់ពន្ធនាគារ២៥ឆ្នាំ ពីបទៈ ជួញដូរដោយខុសច្បា
នូវសារធាតុញៀន ជានីតិជន។ (ក្នុងឃុំ)

៧. ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរ
កម្មករ ទីកន្លែងកំណើតភូមិក្របីរៀល ឃុំក្របីរៀល ស្រុកពួក ខេត្តសៀមរាប លំនៅបច្ចុប្បន្នភូមិបន្ទា
មានរិទ្ធ [redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] (លែងលះ) ឪពុ
ឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ·ស· ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ០៦ឆ្នាំ ពីបទៈ ជួញដូ
ដោយខុសច្បាប់នូវសារធាតុញៀន ជានីតិជន។ (ក្នុងឃុំ)

៨. ឈ្មោះ [redacted] សាវ៉ែន ហៅ ម៉ាប់ ហៅ ខ្សែន ភេទប្រុស កើតឆ្នាំ១៩៩២ សញ្ជាតិខ្មែ
សាសនាព្រះពុទ្ធ មុខរបរ គ្មាន ទីកន្លែងកំណើតភូមិគោកក្នុង ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង
ចាម ទីលំនៅបច្ចុប្បន្ន [redacted] ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នៅលីវ ឪពុក
ឈ្មោះ [redacted] ·ར· ម្ដាយឈ្មោះ [redacted] ·ར· ទោសពីមុនគ្មាន ជានីតិជន។ (ក្នុងឃុំ)

៩. ឈ្មោះ [redacted] ណាវ៉ែន ភេទស្រី កើតឆ្នាំ១៩៨៩ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ
និស្សិត ទីកន្លែងកំណើតភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនសាយ ខេត្តកណ្ដាល ទីលំនៅបច្
[redacted] ស្រុកកៀនស្វាយ ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះ [redacted] ·ར·
ម្ដាយឈ្មោះ [redacted] ·ར· ទោសពីមុន គ្មាន ជានីតិជន។ (ក្រៅឃុំ)

**ត្រូវចោទពីបទ ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សំអាតប្រាក់ ប្រព្រឹត្ត
នៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុង
សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទ
ល្មើសមានចែង និងផ្ដន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការ
ត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៤០៤ និងមាត្រា៤០៦ នៃក្រមព្រហ្មទណ្ឌ។

១០. ឈ្មោះ [redacted] សីហា ហៅ គិត ភេទប្រុស កើតឆ្នាំ១៩៨២ មុខរបរកម្មករ សញ្ជាតិខ្មែរ
ទីកន្លែងកំណើតភូមិតាំងក្រង ឃុំតាំងក្រង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នភូមិតាំង
[redacted] ខេត្តកំពង់ធំ ឪពុកឈ្មោ [redacted] ·ར· ម្ដាយឈ្មោះ ជ [redacted] ·ར·
ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ០៦ឆ្នាំ ជានីតិជន។ (ក្នុងឃុំ)

**ត្រូវចោទពីបទ ៖** សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត
នៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុង
សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទ
ល្មើសមានចែង និងផ្ដន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការ
ត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

**អង្គហេតុដែលប្រកាន់មានដូចតទៅ** ៖ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ វេ ម៉ោង១៥ និង៤៥នាទី ស្ថិតនៅចំណុចភូមិភ្នំកន្ទួត សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទា មានជ័យ ដោយអនុវត្តដៃពានញុះញង់ឲ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន កម្លាំងការិយាល័ បទល្មើសគ្រឿងញៀន បានចុះធ្វើប្រតិបត្តិការណ៍បង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធា ញៀន ដោយធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន០១នាក់ឈ្មោះ[redacted]ចំរើន ហៅ ណុយ ភេទប្រុស អា ១៧ឆ្នាំ តាមការស្តាប់ចម្លើយ និងសហការណ៍ចង្អុលបង្ហាញពីជនសង្ស័យឈ្មោះ[redacted] ចំរើន ម៉ោង១ និង៣០នាទី នៅចំណុចភូមិកោះ ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កម្លាំងយើងសហការណ៍ ជាមួយកម្លាំងកងរាជអាវុធហត្ថខេត្តបាត់ដំបង បានបន្តប្រតិបត្តិការណ៍បង្ក្រាបឃាត់ខ្លួនជនសង្ស័យបា ចំនួន០១នាក់ទៀត ដែលមានឈ្មោះ[redacted]រ៉ូហ្វា ភេទស្រី អាយុ២៤ឆ្នាំ ហើយឈ្មោះ [redacted] រ៉ូហ្វា បា សហការណ៍ជាមួយកំលាំងសមត្ថកិច្ចកងរាជអាវុធហត្ថ រួចបន្តការឃាត់ខ្លួនមេខ្លោងធំដទៃទៀត ដែល ជាទណ្ឌិតនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យជាបន្តបន្ទាប់បានចំនួន០៧នាក់ទៀត ដែលមានឈ្មោ [redacted]មន្នី ភេទស្រី អាយុ៣២ឆ្នាំ, ឈ្មោះ[redacted] សារ៉ែន ភេទប្រុស អាយុ៤៤ឆ្នាំ, ឈ្មោះ [redacted]នាង ភេទ ប្រុស អាយុ៥០ឆ្នាំ, ឈ្មោះ[redacted] លីហៀង ភេទប្រុស អាយុ៣៣ឆ្នាំ, ឈ្មោះ[redacted] ហេង ភេទប្រុស អាយុ ២៩ឆ្នាំ, ឈ្មោះ [redacted]ប៊ីហា ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ [redacted]សារី ភេទប្រុស អាយុ៣៦ឆ្នាំ។ បន្ទាប់មកនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ សមត្ថកិច្ចបានចុះទៅទីតាំងអគារជួល ដែលមាន១៨បន្ទប់ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិរបស់ឈ្មោះ[redacted] នាង ហៅ [redacted] វណ្ណដា និងប្រពន្ធឈ្មោះ [redacted] មន្នី បានធ្វើការឆែកឆេរបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] មន្នី និងឆែកឆេរបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] ណារ៉ែន ភេទស្រី អាយុ៤៤ឆ្នាំ រឹបអូសបាន វត្ថុតាងមួយចំនួនធំ ហើយសមត្ថកិច្ចបានសម្រេចបិទទីតាំងអគារជួលទាំងមូលតែម្តង។ អគារជួល និង វត្ថុតាងដែលចាប់យកទាំងអស់ គឺបានមកពីអំពើល្មើសក្នុងបទល្មើសគ្រឿងញៀនដើម្បីសម្អាតប្រាក់។

**នាពេលសវនាការ**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទដែលមានវត្តមាន

-ក្រោយពីបានពិនិត្យឯកសារ និងកស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

**ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តបន្ទាយមានជ័យ យល់ឃើញថា ៖**



Scanned with CamScanner

១. ជនជាប់ចោទឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ (អត្តសញ្ញាណខ
លើ) ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវស
ជាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡ
ខែឧសភា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានទែង និងផ្តន្ទាទោសតាមមាត្រ
៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សា ហៅ ស៊ីណា ហៅ ម៉ុំ ភេទស្រី អាយុ២៤ឆ្នាំ (អត្តសញ្ញាណ
ខាងលើ) ត្រូវបានចៅក្រមបញ្ជូនមកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹ
នៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្
២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានទែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ
និងមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. ជនជាប់ចោទឈ្មោះ [redacted] នាង (ឈ្មួនវណ្ណដា) ភេទប្រុស អាយុ៥០ឆ្នាំ, ឈ្មោះ [redacted] មន្ត
ហៅ ថៃ នី ភេទស្រី អាយុ៣២ឆ្នាំ, ឈ្មោះ [redacted] លីហៀង ហៅ ហៀង ភេទប្រុស អាយុ៣៤ឆ្នាំ, ឈ្មោះ [redacted]
សាវី ហៅ បាក់ ភេទប្រុស កើតឆ្នាំ១៩៨០, ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៩ឆ្នាំ, ឈ្មោះ [redacted]
សាវ៉ែន ហៅ ម៉ាប់ ហៅ ឡែន ភេទប្រុស កើតឆ្នាំ១៩៩២ និងឈ្មោះ [redacted] ណាវ៉ែន ភេទស្រី កើតឆ្
១៩៨៩ (អត្តសញ្ញាណខាងលើ) ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ ជួញដូរដោយខុស
ច្បាប់នូវសារធាតុញៀន និង សំអាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុច
បន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ
២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានទែង និងផ្តន្ទាទោសតាមមាត្រា៤០ កថា
ខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៤០៤ និងមាត្រា
៤០៦ នៃក្រមព្រហ្មទណ្ឌ។

៤. ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ គិត ភេទប្រុស កើតឆ្នាំ១៩៨២ (អត្តសញ្ញាណខាង
លើ) ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវ
សារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិ
ទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី
១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានទែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥
ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

៥. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ចំរើន ឆ្លើយថា ខ្លួនធ្លាប់ឆ្លើយសារភាពហើយៗក៏
ទទួលស្គាល់ការចោទប្រកាន់ដែរ។ នៅថ្ងៃនោះមិត្តភក្តិបានគេបបួលខ្លួនទិញថ្នាំញៀនជក់ តែពេលហៅប៉េ
អឹមមកចាប់ខ្លួនៗក៏សហការណ៍ចាប់បន្ត តែខ្លួនមិនដែលទិញថ្នាំញៀនលក់ទេ ធ្លាប់តែប្រើប្រាស់ជាច្រើន

ដង ដោយខ្លួនទិញម្តងមួយកញ្ចប់តម្លៃប្រាំមួយទៅប្រាំបីម៉ឺនរៀល ដោយលុយចូលគ្នាហើយទៅទិញ ឈ្មោះ ផុន([redacted] កុសស-គ្មានសាវតារជាតិគ្រប់គ្រាន់) ក្រៅពីនេះមិនមានទិញពីអ្នកណាទេ។ ចំណែក ឈ្មោះ [redacted] រ៉ូហ្សា ខ្លួនមិនស្គាល់ទេ ខ្លួនស្គាល់តែឈ្មោះ ផុន។ ពេលដែលខ្លួនជូនសមត្ថកិច្ចទៅរកចា ឈ្មោះ ផុនៗក៏រត់ចោលផ្ទះ ដោយទុកទូរស័ព្ទចោល ហើយស្របពេលមានគេ[redacted] រ៉ូហ្សា) តេមកសម កិច្ចក៏ឲ្យខ្លួនលើកដោយបន្ទំថាខ្លួនជាឈ្មោះ ផុន ហើយឲ្យកម្ម៉ង់ទិញថ្នាំញៀនតម្លៃ៧០ម៉ឺនរៀល រួ សមត្ថកិច្ចឲ្យខ្លួនជូនទៅតាមចាប់ដោយណាត់ជួបនៅបន្ទាយនាង តែពេលទៅជួបឈ្មោះ[redacted] រ៉ូហ្ ដឹងខ្លួនថាមិនមែនជាឈ្មោះ ផុន ក៏បើកឡានរត់គេច សមត្ថកិច្ចតាមចាប់ខ្លួនបាន។ ចំពោះឈ្មោះ ផុ គឺជា [redacted] កុសល ខ្លួនស្គាល់ពេលចូលរៀនបានមួយឆ្នាំជាង តាមរយៈមិត្តភក្តិឈ្មោះ កា ជាអ្នកណែ នាំឲ្យស្គាល់ ដោយខ្លួនស្គាល់គ្រាន់តែទាក់ទងទិញថ្នាំញៀនពីវាប៉ុណ្ណោះ។ ពេលខ្លួនទៅយកថ្នាំញៀនពី វា(ផេង កុសល) វាអត់មានម៉ូតូជិះ វាក៏ឲ្យជូនទៅដោយថាទៅទិញអីហូប តែពេលទៅដល់ ខ្លួនឃើញវ យកថ្នាំញៀនលក់ឲ្យគេជាច្រើនដង ហើយគេឲ្យខ្លួនប្រើប្រាស់ថ្នាំញៀន។

៦. នាពេលសវនាការជនជាប់ចោទឈ្មោះ[redacted] រ៉ូហ្សា ឆ្លើយថា ៖ ចម្លើយរបស់ខ្លួនទាំងប៉ុន្មាន ជាការពិត។ ខ្លួនជួញដូរគ្រឿងញៀនបាន៤ដងហើយ ដោយដំបូងខ្លួនស្គាល់ឈ្មោះ [redacted] នាង នៅក្នុង គុក ដល់ពេលខ្លួនចេញពីគុក ខ្លួនបានទៅសួរសុខទុក្ខឈ្មោះ [redacted] នាង ក្នុងពន្ធនាគារ ហើយគាត់កុហក់ ខ្លួនថាគាត់មិនមានប្រពន្ធទេ បែរជាគាត់ទាក់ទងខ្លួនឲ្យជួយកាន់ថ្នាំញៀនយកទៅលក់ឲ្យម៉ូយរបស់គាត់ ហើយបានលុយយកមកឲ្យគាត់វិញទាំងអស់។ តែលើកចុងក្រោយនេះដោយសារតែ[redacted] នាង មិនបាន ឲ្យលុយខ្លួនពីរបីខែមកហើយ ទើបខ្លួនយកលក់ដោយខ្លួនឯងដើម្បីបានលុយខ្វះ។ លក់ថ្នាំឲ្យ [redacted] នាង ម្តងៗមានទម្ងន់ប្រហែលជា៦-៧ជីខ្មែរ ជាលុយបានបីលានរៀលជាង ដោយខ្លួនលក់ឲ្យអ្នកប្រើប្រាស់។ ចំពោះថ្នាំញៀនគឺឈ្មោះ [redacted] នាង ឲ្យប្អូន និងកូនចៅគាត់មានឈ្មោះ ផល និងឈ្មោះ សារ៉ែន ជាប្អូន ថ្លៃគាត់យកមកឲ្យខ្លួន ចំណែកលុយថ្លៃថ្នាំញៀន ជូនកាលខ្លួនយកឲ្យក្នុងពន្ធនាគារ ជួនកាលវេរតាមវីង ហើយគាត់ឲ្យប្អូនថ្លៃគាត់បើកឲ្យ ហើយ [redacted] នាង ទំនាក់ទំនងជាមួយខ្លួនតាមរយៈទូរស័ព្ទ ដែលឈ្មោះ [redacted] នាង អាចប្រើបានចន្លោះពីម៉ោងប្រាំមួយល្ងាចដល់ប្រាំមួយព្រឹក និងពេលថ្ងៃត្រង់ចន្លោះពីម៉ោង ដប់ពីរដល់ម៉ោងពីរ ដែលការទាក់ទងគឺនិយាយសួរសុខទុក្ខ និងនិយាយរឿងថ្នាំញៀន ព្រោះខ្លួនមាន ទំនាក់ទំនងស្នេហាជាមួយឈ្មោះ[redacted] នាង។ ពេលខ្លួនវេរលុយឲ្យឈ្មោះ [redacted] នាង ហៅលេខកូដឲ្យលី សំលេងមនុស្សស្រីតែមិនដឹងថាជានណាទេ។ ចំណែកប្រពន្ធ[redacted] នាង ខ្លួនទើបតែស្គាល់ពេលដែល សមត្ថកិច្ចចុះឆែកឆេរផ្ទះ។ ចំពោះឈ្មោះ ផុន ហៅ [redacted] កុសល ខ្លួនមិនស្គាល់ទេ។ ចំពោះថេយន្ត ខ្លួនគឺ អ្នកចិញ្ចឹមខ្លួនពីមុនដែលស្លាប់ទៅហើយជាអ្នកទិញឲ្យ ដែលឡានទេះខ្លួនយកដឹកថ្នាំញៀនម្តងម្កាល។ ជនជាប់ចោទឈ្មោះ សារី[redacted] សារ៉ា ថាពេលខ្លួនចេញទៅវិញមិនឲ្យចខ្លួនទេ ព្រោះដោយសារតែខ្លួន ធ្វើឲ្យមានការពាក់ព័ន្ធដល់រូបគាត់ និងធ្វើឲ្យគាត់ខាតលុយ ឈ្មោះ សារី នេះមានទំនាក់ទំនងជាមួយ



Scanned with CamScanner

ឈ្មោះ [redacted] នាង ហៅ ដា។ ខ្លួនមានការភ័យខ្លាចចំពោះសុវត្ថិភាព ព្រោះសូម្បីតែប្អូនថ្លៃរបស់ [redacted] ឈ្មោះ សាវ៉ែន បានបោះពាក្យថា ចេញទៅវិញគឺបានស៊ីគ្រាប់សំណហើយ សូម្បី [redacted] នាង ក៏និយា ដែរថា ឲ្យតែនៅខេត្តបន្ទាយមានជ័យ បាត់ដំបង នឹងឲ្យកូនចៅតាមកេឲ្យឃើញ។ ហើយក្នុងពន្ធនាគ ដោយសារតែខ្លួនឆ្លើយដាក់ [redacted] នាង ប្រធានពន្ធនាគារខឹងនឹងខ្លួន តាមសង្កត់ខ្លួនថាដោយសារតែខ្លួ ធ្វើឲ្យបាត់ចំណូលក្នុងពន្ធនាគារ។

៧. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] លីហៀង ឆ្លើយថា ៖ ខ្លួនជាប់ពន្ធនាគារនេ ប្រទេសថៃ ដោយតុលាការថៃកាត់ទោសម្ភៃប្រាំឆ្នាំ ហើយត្រូវបានផ្ទេរមកខ្មែរវិញ។ ចំពោះចម្លើយខ្លួន មុនមិនមានការបង្ខិតបង្ខំ ឬគំរាមកំហែងទេ គ្រាន់តែពេលអានឲ្យស្តាប់ ចំណុចខ្លួនជំទាស់ដែរតែសមត្ថ កិច្ចមិនព្រម។ ចំណែកចម្លើយនៅតុលាការគឺសុទ្ធតែពិត។ ខ្លួនស្គាល់ម្នាក់ស្រីឈ្មោះ [redacted] រ៉ូហ្សា នេ ដោយសារតែឃើញគាត់មកជួបជាមួយ [redacted] នាង មួយអាទិត្យ ឬមួយខែម្តង។ ចំណែកឈ្មោះ គឹម សា ឈ្មោះ [redacted] សីហា, ឈ្មោះ ហេង, ឈ្មោះ [redacted] នាង ធ្វើការ និងនៅក្នុងបន្ទប់ពន្ធនាគារជាមួយគ្នា។ ក្នុង ពន្ធនាគារឈ្មោះ សារី ប្រើទូរស័ព្ទ១គ្រឿង, ឈ្មោះ [redacted] នាង ប្រើដែរ ឈ្មោះ ហេង ខ្លួនមិនច្បាស់ទេ ហើយឈ្មោះ សីហា ក៏មានដែរ និងធ្លាប់ឃើញពួកគាត់ឆ្លើយឆ្លងទូរស័ព្ទ តែមិនដឹងថាទាក់ទងអ្វីឡើយ។ ចំពោះចម្លើយដែលខ្លួនឆ្លើយថា ធ្លាប់លឺថាឲ្យយកឥវ៉ាន់នោះ គឺឈ្មោះ [redacted] នាង ប្រើឲ្យប្អូនថ្លៃគាត់យក ឥវ៉ាន សំដៅលើក្រដាសខាត់ឈើ និងឧបករណ៍ផ្សេងៗសម្រាប់កន្ទៃងជាង។ ចំពោះ [redacted] ណាវ៉ែន ខ្លួន ស្គាល់ព្រោះធ្លាប់មានទំនាក់ទំនងស្រឡាញ់គ្នា ហើយក៏ស្គាល់តាមរយៈមិត្តភក្តិណែនាំដែរ។ ឈ្មោះ [redacted] ណាវ៉ែន មិនមានទំនាក់ទំនងអ្វីជាមួយ [redacted] នាង ទេ។ ចំពោះឈ្មោះ [redacted] ណាវ៉ែន គឺឈ្មោះ សារី ប្រើឲ្យទិញម្ហូប ពេលប្រមូលលុយគ្នាបានហើយក៏អ្នកជាប់ពន្ធនាគារប្រើឲ្យដកលុយវេរតាមវីង ពេលបង ប្អូនគេផ្ញើរឲ្យដែរ។ ខ្លួនត្រូវបានម្តាយខ្លួន និងឈ្មោះ [redacted] នាង សុំឲ្យមកធ្វើការងារពេងជាងជាមួយ [redacted] នាង។ នៅក្នុងពន្ធនាគារធ្លាប់មានស្ត្រីម្នាក់ឈ្មោះ មុំ មកទារលុយពី [redacted] នាង។ ហើយរឿងជំពាក់លុយ នេះដោយសារតែរឿងផ្ទះជួល។ ចំពោះផ្ទះជួល ធ្លាប់លឺឈ្មោះ [redacted] នាង និយាយជាសាធារណៈថា លុយ គឺបានមកពីលែងលះជាមួយប្រពន្ធមុន។

៨. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] មន្នី ឆ្លើយថា ខ្លួនជាប្រពន្ធ [redacted] នាង ដែល បានទំនាក់ទំនងគ្នាតាំងពីនៅថៃ ហើយក៏ជាម្ចាស់ផ្ទះជួលដែលត្រូវបានបិទផងដែរ ចំពោះលុយខ្លួនមិន មានទេ គឺជាលុយរបស់ប្តីខ្លួនឈ្មោះ [redacted] នាង។ ដីជារបស់ឈ្មោះ [redacted] នាង ដែលបានលុយពីការលែង លះជាមួយប្រពន្ធមុន។ ដីមានទំហំ២៥ម៉ែត្រគុណ៤០ម៉ែត្រ ទិញពីរម៉ឺនដុល្លា ដោយខ្លួនជាអ្នកទិញ និង ធ្វើផ្ទះអស់តម្លៃប្រហែលជាជប់ពីរម៉ឺនដុល្លាដាក់ឈ្មោះខ្លួន តែលុយជារបស់ [redacted] នាង ទាំងអស់ ហើយ លុយគឺខ្លួនទទួលពីឈ្មោះ [redacted] ពៅ ជាប្អូនគាត់ ដែលជូនកាលគាត់វេរឲ្យតាមវីង ជួនកាលយកមកឲ្យ ផ្ទាល់។ [redacted] នាង ក៏មានខ្ចីលុយពីរម៉ឺនដុល្លាពីប្រពន្ធដើមគាត់ឈ្មោ [redacted] មុំ ដើម្បីយកមកឲ្យថ្លៃឥវ៉ាន់ធ្វើ ៤



Scanned with CamScanner

191

ផ្ទះផងដែរ ដែលលុយនេះប្រពន្ធដើមគាត់យកទៅឲ្យគាត់នៅពន្ធនាគារ រួច [redacted] នាង ប្រើក្មួយគេ ឈ្មោះ[redacted] សំណាង យកមកឲ្យខ្លួន។ ចំពោះឈ្មោះ [redacted] រ៉ូហ្សា មុនពេលកើតហេតុគាត់បានទំនាក់ ទំនងមកខ្លួនអះអាងថាជាប្រពន្ធរបស់ឈ្មោះ [redacted]នាង ([redacted]ក់ន់ដា)។

៩. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន ឆ្លើយថា ៖ ចម្លើយពីមុនខ្លួនមិនបាន សេចទេ។ ខ្លួនធ្លាប់យកថ្នាំញៀនឲ្យគេបីដងដោយយកពីបងដា(ពេន នាង) ដោយគេយកមកឲ្យខ្លួនតាម រយៈការប្ដុងចោលនៅស្ពានទឹកថ្លា ហើយខ្លួនយកទៅឲ្យឈ្មោះ [redacted]រ៉ូហ្សា ទាំងបីលើក ដោយទំនាក់ ទំនងគ្នាតាមទូរស័ព្ទ អត់មានយកប្រាក់មកវិញទេ ព្រោះប្រើឲ្យតែយកឲ្យប៉ុណ្ណោះ។ ខ្លួនមិនដែលធ្លាប់ យកគ្រឿងញៀនចេញពីពន្ធនាគារទេ។ ពេល [redacted]នាង ប្រើគឺតាមទូរស័ព្ទ។ ពេលដែលខ្លួនធ្វើ សារ មន្ទីរ មិនដឹងទេ ហើយខ្លួនក៏មិនដែលនិយាយប្រាប់គាត់ដែរ។ [redacted]នាង ក៏មិនបានឲ្យកំរៃខ្លួនដែរ។

១០. នាពេលសវនាការជនជាប់ចោទឈ្មោ[redacted]សារី ឆ្លើយថាឈ្មោះ[redacted]ណាវ៉ែន ខ្លួនស្គាល់ នៅកន្លែងសិប្បកម្ម ដែលខ្លួនឲ្យលុយជួយទិញម្ហូបអាហារឲ្យ និងនាងត្រូវជាសង្សាររបស់ [redacted]លីហៀង។ ចំពោះលុយគឺប្រពន្ធខ្លួនផ្ញើឲ្យ។ ខ្លួនមកធ្វើសិប្បកម្មជួយការងារ [redacted]នាង បានប្អូនខែ។ [redacted]នាង មិន ដែលប្រើឲ្យយកថ្នាំញៀនទេ ហើយក៏មិនដែលឃើញ [redacted] នាង ប្រើមនុស្សឲ្យយកថ្នាំញៀនដែរ។ ចំពោះប្អូនថ្លៃ[redacted]នាង[redacted]សាវ៉ែន) ខ្លួនធ្លាប់ជួបនៅកន្លែងសិប្បកម្ម។ ចំពោះប្រពន្ធ[redacted] នាង ខ្លួនក៏ ធ្លាប់ឃើញមកលេងដែរ ទាំងប្រពន្ធដើម និងប្រពន្ធចុង។ ខ្លួនដឹងខុសហើយ លួចប្រើទូរស័ព្ទពីរគ្រឿង មានសាំសុង និងអិនចុចពិល ដែលការប្រើគ្រាន់តែទុកទាក់ទងបងប្អូន និងប្រពន្ធដែលជាជនជាតិឡាវ។ ចំពោះវិក័យប័ត្រវីងរបស់ឈ្មោះ [redacted]ណាវ៉ែន ខ្លួនមិនដឹងទេ។

១១. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted]ហេង ឆ្លើយថា ខ្លួននៅបន្ទប់លេខ២ ជាអ្នក ដាំបាយធ្វើម្ហូប។ ខ្លួនមានប្រើទូរស័ព្ទទុកតេទៅបងប្អូន។ ដែលទូរស័ព្ទគឺមិត្តភ័ក្រឈ្មោះ យី យកមកឲ្យ។ ចំពោះអ្នកផ្សេងដែលប្រើទូរស័ព្ទក្នុងបន្ទប់ខ្លួនមិនដែលបានសង្កេតមើលទេ។ ខ្លួនឃើញឈ្មោះ ដា និង ឈ្មោះ ហៀង និយាយគ្នាធម្មតា មិនដែលលឺនិយាយរឿងឥវ៉ាន់អ្វីទេ។ ខ្លួនមិនបានយកថ្នាំញៀនទេ។

១២. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted]បីហា ឆ្លើយថាខ្លួននៅបន្ទប់រួមគ្នាជាមួយគេ បានយូរខែដែរហើយ ដោយខ្លួនមានតួនាទីជាអ្នកដាំបាយធ្វើម្ហូប ហើយម្ហូបគេទិញយកមកឲ្យ ហើយ ប៉ូលីសពន្ធនាគារយកមកឲ្យ។ ខ្លួនមានទូរស័ព្ទមួយគ្រឿងទុកគ្រាន់ទាក់ទងម៉ែឪបងប្អូន។ មេក្រុមសិប្ប កម្មគឺ បងដា[redacted] នាង)។ រឿងលុយចេញចូលខ្លួនមិនដឹងទេ ដឹងថារឿងលុយគឺ បងដា ចាត់ចែង។ រឿង គាត់រកស៊ីថ្នាំញៀនខ្លួនមិនដឹងទេ ដឹងតែគាត់ជាប់គុករឿងគ្រឿងញៀន។ ខ្លួនធ្លាប់លឺបងដា និយាយរឿង លុយទិញដី ដោយនិយាយកន្លែងសិប្បកម្មថា គាត់មានដី។ ខ្លួនអត់ឃើញឈ្មោះ ហៀង និងឈ្មោះ ដា និយាយគ្នាស្ងាត់ៗទេ។ បងដា ជាអ្នកសុំឲ្យខ្លួនចេញទៅធ្វើការនៅសិប្បកម្មជាមួយ។

១៣. តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា បញ្ជាក់
កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០១៦ ខ្លួនបានចាប់ផ្តើមទិញថ្នាំញៀនពីឈ្មោះ ង៉ៃ ភេទស្រី អាយុ៤០ឆ្នាំ
ជាតិថៃ ដែលមិត្តភ័ក្ររបស់ខ្លួននៅប្រទេសថៃឲ្យលេខឈ្មោះ ង៉ៃ ស្នាក់នៅប៉ោយប៉ែត ពេលនោះខ្លួ
បានទិញចំនួនពីរដីខ្មៅ ក្នុងតម្លៃហុកសិបម៉ឺនរៀល ហើយខ្លួនយកមកលក់បន្តឲ្យឈ្មោះ [redacted] រ៉ូហ្
ហៅ មុំ ក្នុងតម្លៃសែសិបម៉ឺនរៀលក្នុងមួយដីខ្មៅ ពេលនោះខ្លួនឲ្យប្អូនថ្លៃខ្លួនឈ្មោះ [redacted] ឡែន ជាអ្ន
យកទៅឲ្យឈ្មោះ [redacted] រ៉ូហ្សា ចំណែកលុយថ្លៃទិញឈ្មោះ [redacted] រ៉ូហ្សា វេរតាមវីង និងយកមកឲ្យខ្លួនន
ពន្ធនាគារ។ ខ្លួនលក់ថ្នាំញៀនទៅឲ្យឈ្មោះ ទេស រ៉ូហ្សា បានចំនួន៤ដងគត់ ហើយចុងក្រោយនៅអំឡុ
ពាក់កណ្តាលខែមិថុនា ឆ្នាំ២០១៦ ចំនួន៦ដីខ្មៅក្នុងតម្លៃ៦០០ដុល្លាទៅឲ្យឈ្មោះ ទេស រ៉ូហ្សា ហើយ
ពេលនោះគឺខ្លួនឲ្យឈ្មោះ ផល ភេទប្រុស ជាអ្នកយកទៅឲ្យឈ្មោះ [redacted] រ៉ូហ្សា ចាប់ពីពេលនោះមក ខ្លួ
មិនដែលបានលក់ឲ្យឈ្មោះ [redacted] រ៉ូហ្សា ទៀតទេ។ ខ្លួនសូមឆ្លើយបដិសេធថា នៅថ្ងៃទី១០ ខែកញ្ញា ឆ្
២០១៦ ខ្លួនមិនបានលក់គ្រឿងញៀនឲ្យឈ្មោះ [redacted] រ៉ូហ្សា នោះទេ។ ចំណែកថ្នាំញៀនដែលដកហូ
បានពីឈ្មោះ [redacted] រ៉ូហ្សា នោះប្រហែលជាឈ្មោះ [redacted] រ៉ូហ្សា ទិញពីអ្នកផ្សេង។ ចំពោះប្រពន្ធរបស់ខ្លួ
ឈ្មោះ [redacted] មន្នី គឺមិនបានដឹងថាខ្លួនលក់គ្រឿងញៀននោះទេ ហើយចំណែកលុយដែលខ្លួនបានឲ្
ប្រពន្ធរបស់ខ្លួនទិញដី និងធ្វើបន្ទប់ជួលនោះ គឺខ្លួនបានមកពីលក់ដី និងផ្ទះនៅខ្សែម បានចំនួន ៤.៨០០
០០០(បួនលានប៉ែតសិបម៉ឺន)បាត ហើយលុយដែលខ្លួនលក់គ្រឿងញៀននោះគឺខ្លួនយកទៅប្រើប្រាស់
ក្នុងពន្ធនាគារដើម្បីចាយវាយនៅទីនោះ។ ក្នុងរឿងនេះខ្លួនសំណូមពរបើកផ្ទះឲ្យប្រពន្ធកូនខ្លួនស្នាក់នៅ
ផង ព្រោះមិនពាក់ព័ន្ធនឹងប្រាក់រកស៊ីគ្រឿងញៀននោះទេ។

១៤. តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា, ឈ្មោះ
[redacted] រ៉ូហ្សា, ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] សាវ៉ែន បានឆ្លើយសារភាពនូវអំពើប្រព្រឹត្តដែលអាចឲ្យ
ជឿជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន
ដូចការចោទប្រកាន់ព្រាកដមែន។

១៥. ជនជាប់ចោទឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ហង និងឈ្មោះ [redacted] លីហៀង គឺជាអ្នកស្នាក់
នៅក្នុងបន្ទប់ និងធ្វើការក្នុងរោងសិប្បកម្មជាមួយនឹងឈ្មោះ [redacted] នាង ហើយការដែលបានមកស្នាក់នៅ
និងធ្វើការសុទ្ធតែដោយសារជនជាប់ចោទឈ្មោះ [redacted] នាង ជាអ្នកសុំមកទាំងអស់ទើបបាន សូម្បីតែ
ឪពុកម្តាយរបស់ខ្លួនសុំឲ្យមកធ្វើការក៏មិនបានដែរ ដែលនេះបញ្ជាក់ថាឈ្មោះ [redacted] សារី, ឈ្មោះ [redacted]
ហង និងឈ្មោះ [redacted] លីហៀង បានឯកភាពយល់ព្រមធ្វើជាសហការី ឬអ្នកនៅក្រោមបង្គាប់បញ្ជារបស់
ឈ្មោះ [redacted] នាង និងសុទ្ធតែជាមនុស្សដែលឈ្មោះ [redacted] នាង ទុកចិត្តបំផុតទៀតផង។

១៦. ជនជាប់ចោទឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ហង និងឈ្មោះ [redacted] លីហៀង ទាំងស្នាក់នៅ
និងធ្វើការជាមួយជនជាប់ចោទឈ្មោះ [redacted] នាង រហូតដូចដែលឈ្មោះ [redacted] នាង បានសារភាពថា ខ្លួន

កម្ពុជាវិញថ្នាំញៀនគឺតាមរយៈទូរស័ព្ទ ដែលចំណុចនេះបញ្ជាក់ថាទាំងអស់គ្នាសុទ្ធតែបានដឹង និងបា លីយ៉ាងច្បាស់ ហើយថែមទាំងសហការណ៍ចូលរួមប្រព្រឹត្តជាមួយនឹងឈ្មោះ [redacted] នាង ទៀតផង។

១៧. ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ហេង ឈ្មោះ [redacted] ព ហៀង និងឈ្មោះ [redacted] នាង គឺជាចម្លើយដោះសារដើម្បីជួយគ្នីគ្នាដែលជាបក្ខពួកតែមួយឲ្យរួចផុតពីកា ចោទប្រកាន់តែប៉ុណ្ណោះ។

១៨. ជនជាប់ចោទឈ្មោះ [redacted] ណាវ៉ែន គឺជាអ្នកនៅក្រៅពន្ធនាគារ និងបានស្នាក់នៅបន្ទប់ ជួលរបស់ឈ្មោះ [redacted] មន្នី ក្នុងរូបភាពដើម្បីបន្លំក្លែងធ្វើជាការចូលសួរសុខទុក្ខ ទិញម្ហូបអាហារនិង ឥវ៉ាន់ផ្សេងៗឲ្យក្រុមរបស់ឈ្មោះ [redacted] នាង តែតាមការពិតគឺទៅក្នុងគោលបំណងរត់ការបើកលុយរេ តាមវីង តាមរយៈការដើរតួជាស្នងព្រារបស់ឈ្មោះ [redacted] លីហៀង និងធ្វើការទាក់ទងជាមួយឈ្មោះ [redacted] សារ ក្នុងការប្រគល់ទទួលលុយ និងឥវ៉ាន់ រួមទាំងថ្នាំញៀនផង ដែលក្រោយពីមានការចាប់ខ្លួនបក្ខពួករបស់ ឈ្មោះ [redacted] នាង បានហើយ ជនជាប់ចោទឈ្មោះ [redacted] ណាវ៉ែន បានរត់គេចខ្លួនពីសមត្ថកិច្ច រហូត សមត្ថកិច្ចធ្វើការឆែកឆេររកឃើញនូវសៀវភៅគណនីធនាគារ និងវិក្កយប័ត្រវីងនៅក្នុងបន្ទប់ជួលរបស់ ឈ្មោះនេះផ្ទាល់ និងនៅក្នុងផ្ទះជួលរបស់ឈ្មោះ [redacted] មន្នី ដែលជាប្រពន្ធរបស់ឈ្មោះ ពេន នាង។

១៩. ជនជាប់ចោទឈ្មោះ [redacted] មន្នី គឺជាប្រពន្ធជនជាប់ចោទឈ្មោះ [redacted] នាង និងមានកូនជា មួយ ពេន នាង ដល់ទៅបីទៀតផង ហើយជនជាប់ចោទឈ្មោះ [redacted] មន្នី ក៏ជាអ្នកគ្រប់គ្រងលុយកាក់ និងមុខរបររកស៊ីរបស់ជនជាប់ចោទឈ្មោះ [redacted] នាង ទាំងអស់ផងដែរ តួយ៉ាងដូចជាទិញដី សាងសង់ ផ្ទះ និងបន្ទប់ជួលជាដើម។ ពុំមានមូលហេតុណាមួយដែលឈ្មោះនេះមិនដឹងថា ជនជាប់ចោទឈ្មោះ [redacted] នាង ដែលជាទណ្ឌិតកំពុងជាប់ក្នុងពន្ធនាគារបានលុយពីណា ដោយរបៀបណានោះឡើយ សូម្បី តែជនជាប់ចោទឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] លីហៀង បានបញ្ជាក់រួចហើយថា ប្រពន្ធរបស់ឈ្មោះ [redacted] នាង(សាន មុន្នី) ក៏ឧស្សាហ៍ចេញចូលជួបឈ្មោះ [redacted] នាង ដែរ។ ការឆ្លើយដោះ សាររបស់ឈ្មោះ [redacted] មន្នី និងការឆ្លើយដោះបន្ទុកឲ្យប្រពន្ធរបស់ឈ្មោះ [redacted] នាង និងការឆ្លើយជួយ ដោះបន្ទុកឲ្យបងស្រីរបស់ឈ្មោះ [redacted] សាវ៉ែន គឺជាចម្លើយដែលមិនអាចជឿជាក់បាន និងគ្រាន់តែជា ចម្លើយដើម្បីអាចឲ្យឈ្មោះ [redacted] មុន្នី បានរួចផុតពីការចោទប្រកាន់ចំពោះអំពើបង្វែរទ្រព្យដែលបានមក ពីការជួញដូរគ្រឿងញៀនរបស់ក្រុមឈ្មោះ [redacted] នាង និងឲ្យរួចផុតពីការរឹបអូសដី និងផ្ទះតែប៉ុណ្ណោះ។

២០. មានភស្តុតាងស៊ីសង្វាក់គ្នាបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ សាន មន្នី, ឈ្មោះ ហេង ណាវ៉ែន, ឈ្មោះ [redacted] សាវ៉ែន, ឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] សីហា គឺជាក្រុមជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាមួយឈ្មោះ [redacted] នាង ហៅ [redacted] វ៉ាន់ដា យ៉ាងពិតប្រាកដ។ ⓐ

២១. ចំពោះលុយដែលបានមកពីការរកស៊ីគ្រឿងញៀនរបស់ជនជាប់ចោទខាងលើ ត្រូវបាន ជនជាប់ចោទយកមកសំអាតតាមរូបភាពទិញដី សាងសង់ផ្ទះ ធ្វើបន្ទប់ជួល ដែលមានឈ្មោះ[redacted] មន្ទី ជាអ្នកគ្រប់គ្រងជាមួយនឹងប្អូនឈ្មោះ [redacted]សាវ៉ែន និងមានឈ្មោះ [redacted] ណាវ៉ែន ជាអ្នកស្នាក់នៅ វ៉ៃ ឈ្មោះ[redacted]នាង, ឈ្មោះ [redacted]សារី, ឈ្មោះ[redacted] ហេង និងឈ្មោះ[redacted]លីហៀង បានប្រើប្រាស់រូបភាព នៃការបើកសិប្បកម្មក្នុងពន្ធនាគារ និងផ្ទះជួលឲ្យឈ្មោះ[redacted] ណាវ៉ែន ដើម្បីបន្តទំនាក់ទំនងក្នុងកា ផ្តល់ដំណឹងពីការជួញដូរគ្រឿងញៀនឲ្យទៅឈ្មោះ [redacted]ហ្សា ធ្វើការផ្ទេរ និងទទួលប្រាក់ដែលបានពី គ្រឿងញៀនតាមរយៈការទទួលដោយផ្ទាល់ដៃក្នុងពេលជួបសួរសុខទុក្ខនៅក្នុងពន្ធនាគារ ឬវេរតាមវីង។

២២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] នាង ដែលថា ខ្លួនលក់ផ្ទះនៅកំរៀង ខេត្តបាត់ដំបង បានប្រាក់ចំនួន ៤,៨០០,០០០បាត តែតាមរយៈកំណត់ហេតុលក់ផ្តាច់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៤ បញ្ជាក់បានថាឈ្មោះ[redacted] (ណ្ណា[redacted] វ៉ាន់ដា) លក់បានតម្លៃតែ ៣,៨០០,០០០បាតប៉ុណ្ណោះ។

២៣. ទោះបីចម្លើយជនជាប់ចោទឈ្មោះ[redacted] នាង ដែលថាខ្ចីលុយប្រពន្ធដើមឈ្មោះ មុំ ចំនួន បីម៉ឺនដុល្លា និងមានប្រពន្ធដើមឈ្មោះ[redacted]មុំ ធ្វើជាសាក្សីបញ្ជាក់ថាមានភាពស៊ីសង្វាក់គ្នាក៏ពិតមែន តែ នេះពុំមែនជាមូលហេតុដែលអាចឲ្យជឿជាក់បានថាឈ្មោះ[redacted] នាង ហៅ ឈួន វ៉ាន់ដា ដែលជាប្តីដើម និងបានលែងលះគ្នាជាមួយឈ្មោះ[redacted] មុំ រួចហើយ ហើយកំពុងជាប់ពន្ធនាគារផងនោះមានលទ្ធភាព និងសមត្ថភាពដើម្បីខ្ចីលុយពីប្រពន្ធដើមឈ្មោ[redacted] មុំ ដោយឈ្មោះ[redacted] មុំ ព្រមឯកភាពស្មគ្រ័ចិត្តទៅ សុំខ្ចីបំណុលពីធនាគារ និងយកមកប្រាក់ឲ្យឈ្មោះ[redacted] នាង យកទៅបើកសិប្បកម្មកែច្នៃឈើក្នុងពន្ធ នាគារ, ទិញដី សាងសង់ផ្ទះ និងធ្វើបន្ទប់ជួលដែលមានតម្លៃដ៏ច្រើនលើសលុប សម្រាប់រួមរស់ជាមួយ នឹងឈ្មោះ[redacted] មុន្នី ដែលជាប្រពន្ធក្រោយនោះទេ។

២៤. តាមចម្លើយសារភាពរបស់ឈ្មោះ[redacted] មន្នី បានបញ្ជាក់ពីប្រភព និងទំហំនៃប្រាក់ដែល ខ្លួនបានយកទៅប្រើប្រាស់ថាបានមកពីប្តីឈ្មោះ [redacted]នាង។ ការចំណាយទាំងនោះរួមមានចំនួន ០២ម៉ឺន ដុល្លារអាមេរិកសម្រាប់ទិញដី, ១២ម៉ឺនដុល្លារអាមេរិកសម្រាប់សាងសង់ផ្ទះ និងធ្វើបន្ទប់ជួលដោយមិន ទាន់បានរាប់បញ្ចូលទាំងការចំណាយផ្សេងៗក្នុងការបំពាក់សម្ភារសម្រាប់បើកអាជីវកម្មផ្ទះជួលនោះទេ។ ចំនួនការចំណាយនេះ មិនមានលក្ខណៈសមមូលជាមួយនឹងប្រភពចំណូលដូចដែលឈ្មោះ ពេន នាង និងឈ្មោះ [redacted]មន្នី បានឆ្លើយដោះសារនោះទេ ដូច្នេះប្រាក់ដែលមានប្រភពមិនច្បាស់លាស់ និងដែល មិនអាចធ្វើការបកស្រាយបាននេះ អាចឲ្យតុលាការជឿជាក់បានថា គឺជាសកម្មភាពនៃការសំអាតប្រាក់ ដែលទទួលបានពីអំពើជួញដូរគ្រឿងញៀនរបស់ឈ្មោះ [redacted]នាង ។

២៥. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សីហា ជាអ្នកដែលត្រូវបានឈ្មោះ [redacted]នាង ស្នើសុំដោយផ្ទាល់ឲ្យមកធ្វើជាអ្នកដាំបាយ និងធ្វើម្ហូបនៅក្នុងសិប្បកម្មឈើ និងរួមបន្ទប់ជាមួយដែរនោះ ឃើញថាមិនមានភស្តុតាងណាមួយដែលបង្ហាញពីសុចរិតភាពរបស់ឈ្មោះនេះទេ ផ្ទុយទៅវិញការស្នាក់



Scanned with CamScanner

នៅក្នុងបន្ទប់ជាមួយគ្នា ការជួយសម្របសម្រួលតាមរយៈការប្រើប្រាស់ទូរស័ព្ទ ការមិនរាយការណ៍ជូ អនុរក្សពន្ធនាគារ និងការចូលរួមដឹងលឺពីសកម្មភាពតេទូរស័ព្ទទំនាក់ទំនងជួញដូរគ្រឿងញៀនរប ឈ្មោះ [redacted] នាង, ឈ្មោះ [redacted] រី, ឈ្មោះ [redacted] ហៀង, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] សាវ៉ែ ឈ្មោះ [redacted] មុន្នី, ឈ្មោះ [redacted] ណាវ៉ែន និងឈ្មោះ [redacted] រ៉ូហ្សា គឺជាការ ចូលរួមសមគំនិតរបស់ជនជា ចោទឈ្មោះ [redacted] សីហា យ៉ាងពិតប្រាកដ។

២៦. អំពើប្រើប្រាស់ និងជួញដូរថ្នាំញៀនច្រើនដង របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន អា កំណត់បានជាបទ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែ និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ ចំណុច១ និងមាត្រា៤៥ នៃច្បាប់ស្តីពីកា ត្រួតពិនិត្យគ្រឿងញៀន។

២៧. អំពើជួញដូរថ្នាំញៀនរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សា អាចកំណត់បានជាប ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ ៣ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២៨. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] នាង ហៅ [redacted] ន់ដា, ឈ្មោះ [redacted] មុន្នី, ឈ្មោះ [redacted] លីហៀង, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] សារី, ឈ្មោះ [redacted] សាវ៉ែន, និងឈ្មោះ [redacted] ណាវ៉ែន កំណត់បានជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សំអាតប្រាក់ បទល្មើសមានចែង និង ផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង ញៀន និងមាត្រា៤០៤ និងមាត្រា៤០៦ នៃក្រមព្រហ្មទណ្ឌ។

២៩. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សីហា អាចកំណត់បានជាបទ សមគំនិតក្នុងអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ៤ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្ម ទណ្ឌ។

៣០. យោងតាមចម្លើយសារភាព ចម្លើយអ្នកទាក់ទិន វត្ថុចាប់យកបាន និងភស្តុតាងមានក្នុង សំណុំរឿង អាចឲ្យតុលាការជឿជាក់បានថា ពិតជាមានអង្គហេតុនៃអំពើល្មើសដែលបានប្រព្រឹត្តដូច តទៅ៖ ដោយសារតែមានការប្រើវិធានញុះញង់ឲ្យលក់របស់មន្ត្រីនគរបាលយុត្តិធម៌ ទើបឈានដល់ ការចាប់ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ចំរើន ដែលកំពុងធ្វើសកម្មភាពជួញដូរគ្រឿងញៀន រួម ទាំងដកហូតបាននូវវត្ថុតាងជាថ្នាំញៀនផងដែរ។ តាមរយៈចម្លើយសារភាពពីអំពើប្រព្រឹត្តបទល្មើស ប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនរបស់ឈ្មោះ [redacted] ចំរើន ទើបឈានទៅដល់ ការស្រាវជ្រាវរកគូកនរបស់ឈ្មោះនេះ ដែលមានឈ្មោះថា [redacted] កុសល ហៅ ផុន និងបក្ខពួកដែល ត្រូវបានលើកលែងចោទប្រកាន់ដោយមូលហេតុគ្មានសាវតារជាតិគ្រប់គ្រាន់។ តាមរយៈការស្រាវជ្រាវ



Scanned with CamScanner

រកឈ្មោះ [redacted] កុសល មន្ត្រីនគរបាលយុត្តិធម៌បានឲ្យឈ្មោះ [redacted] ចំរើន ដើរតួជាឈ្មោះ [redacted] កុសល
ដើម្បីទិញគ្រឿងញៀនពីឈ្មោះ [redacted] រ៉ូហ្សា តាមទូរស័ព្ទ និងបានណាត់ជួបគ្នាជួញដូរគ្រឿងញៀន
ដោយមានការសង្ស័យនៅពេលធ្វើការជួញដូរគ្រឿងញៀន ថាជាប្រតិបត្តិការណ៍បង្ក្រាបរបស់សមត្ថ
កិច្ចឈ្មោះ [redacted] រ៉ូហ្សា បានជិះរថយន្តរត់គេចខ្លួន តែត្រូវបានសមត្ថកិច្ចដេញតាម និងឃាត់ខ្លួនបាន
រួមទាំងវត្ថុតាងជាសារធាតុញៀនមួយចំនួន។ តាមរយៈចម្លើយសារភាពរបស់ឈ្មោះ ទេស រ៉ូហ្សា បាន
ឈានដល់ការឃាត់ខ្លួនលើឈ្មោះ [redacted] នាង ហៅ [redacted] វណ្ណដា, ឈ្មោះ [redacted] លីហៀង, ឈ្មោះ [redacted]
ហេង, ឈ្មោះ [redacted] សាវី និងឈ្មោះ [redacted] សីហា ដែលកំពុងត្រូវបានអនុវត្តទោសក្នុងពន្ធនាគារ។ ដោយ
ឈ្មោះ [redacted] នាង បានប្រើប្រាស់មនោសញ្ចេតនា សន្យាថានឹងយកឈ្មោះ [redacted] រ៉ូហ្សា ធ្វើជាប្រពន្ធនៅ
ក្រោយពេលចេញពីពន្ធនាគារ បានលួងលោមឲ្យឈ្មោះ [redacted] រ៉ូហ្សា ជួយធ្វើសកម្មភាពជួញដូរគ្រឿង
ញៀនឲ្យខ្លួន។ ឈ្មោះ [redacted] នាង តែងតែប្រើប្រាស់ការទំនាក់ទំនងតាមរយៈទូរស័ព្ទចេញពីពន្ធនាគារ
ជាមួយនឹងអ្នករួមបន្ទប់ដើម្បីកម្មង់ទិញគ្រឿងញៀនពីបក្ខពួកនៅខាងក្រៅ និងដើម្បីប្រគល់គ្រឿង
ញៀនឲ្យទៅឈ្មោះ [redacted] ណាវ៉ែន ដែលជាប្អូនថ្លៃឈ្មោះ [redacted] នាង ឲ្យយកទៅទុកចោលនៅចំណុច
ទីកន្លែង និងបានទូរស័ព្ទឲ្យឈ្មោះ [redacted] រ៉ូហ្សា ទៅយកបន្ត និងធ្វើការជួញដូរបានជាប្រាក់យកមកឲ្យ
ឈ្មោះ [redacted] នាង ដោយផ្ទាល់នៅក្នុងពន្ធនាគារ ឬតាមរយៈការវេរតាមវីង។ តាមរយៈការជួយសម្រប
សម្រួលជាការផ្តល់ទូរសព្ទ័ ការចូលរួមដឹងលឺ ការមិនរាយការណ៍របស់ឈ្មោះ [redacted] សាវី, ឈ្មោះ [redacted]
ហេង, ឈ្មោះ [redacted] លីហៀង និងឈ្មោះ [redacted] សីហា ដែលជាអ្នកជាប់ឃុំនៅក្នុងបន្ទប់ និងរោងសិប្បកម្ម
ឈើតែមួយជាមួយនឹងឈ្មោះ [redacted] នាង បានសហការណ៍គ្នាប្រើប្រាស់ឈ្មោះ [redacted] ណាវ៉ែន ដែលជា
អ្នករស់នៅខាងក្រៅ និងជាមិត្តស្រីរបស់ឈ្មោះ [redacted] លីហៀង ឬឈ្មោះ [redacted] មន្នី ដែលជាប្រពន្ធឈ្មោះ
[redacted] នាង ឲ្យធ្វើសកម្មភាពចេញចូលក្នុងពន្ធនាគារក្នុងរូបភាពសួរសុខទុក្ខ ទិញម្ហូបអាហារ និងសម្ភារ
ផ្គត់ផ្គង់ឲ្យក្រុមរបស់ឈ្មោះ [redacted] នាង ដើម្បីទទួលយកប្រាក់ ឬលេខកូតបើកប្រាក់តាមវីងពីក្រុមរបស់
ឈ្មោះ [redacted] នាង ដើម្បីលាក់ទុក ចាត់ចែង និងចំណាយសម្រាប់ទិញដី សាងសង់ផ្ទះ និងធ្វើជាបន្ទប់
ជួលសម្រាប់ឲ្យឈ្មោះ [redacted] ណាវ៉ែន ស្នាក់នៅ និងបន្តទំនាក់ទំនងក្នុងការជួញដូរគ្រឿងញៀន និង
ប្រគល់ទទួលប្រាក់ជាបន្តបន្ទាប់ រហូតត្រូវបានសមត្ថកិច្ចបំបែកសំណុំរឿងឈានដល់ ការចាប់ឃាត់
ខ្លួន និងបញ្ជូនសំណុំរឿងមកអយ្យការចាត់ការតាមច្បាប់។

៣១. ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សា, ឈ្មោះ [redacted] នាង, ឈ្មោះ [redacted] មុន្នី, ឈ្មោះ [redacted]
សាវ៉ែន, ឈ្មោះ [redacted] ណាវ៉ែន, ឈ្មោះ [redacted] សាវី, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] លីហៀង ជាទីតាំង
ដែលមានសមត្ថភាពក្នុងការយល់ដឹងគ្រប់គ្រាន់ និងអាចទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

៣២. ជនជាប់ចោទឈ្មោះ [redacted] ចំរើន ជាអនីតិជន ប៉ុន្តែមានអាយុគ្រប់តាមកំណត់ច្បាប់ដែ មានការយល់ដឹងគ្រប់គ្រាន់ និងអាចទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន គប្បីពិចារណាជ ការសម្រេចអំពីទោសដូចដែលមានចែងតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៣៣. ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សា បានភ្ញាក់រលឹកចំពោះអំពើប្រព្រឹត្តរបស់ខ្លួន និងបា ផ្តល់កិច្ចសហការណ៍យ៉ាងល្អជាមួយនឹងសមត្ថកិច្ចក្នុងការស្រាវជ្រាវ រហូតឈានដល់ការបង្ហា និ បង្ក្រាបសកម្មភាពជួញដូរគ្រឿងញៀន និងចាប់ឃាត់ខ្លួនឈ្មោះ [redacted] នាង និងបក្ខពួកបានទាំងស្រុ គប្បីពិចារណាផ្តល់នូវការសម្រាលទោសតាមមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣៤. អំពើរបស់ជនជាប់ចោទទាំងអស់ បានប្រព្រឹត្តទាំឲ្យប៉ះពាល់ដល់សុខភាពអ្នកដ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

៣៥. មានជាតុផ្សំបទល្មើស និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទៈ

ក. ឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ (អត្តសញ្ញាណខាងលើ) ពីបទ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

ខ. ជនជប់ចោទឈ្មោះ [redacted] រ៉ូហ្សា ហៅ ស៊ីណា ហៅ មុំ ភេទស្រី អាយុ២៤ឆ្នាំ (អត្តសញ្ញាណខាងលើ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៦ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ កថាខណ្ឌ២ និងមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ. ជនជាប់ចោទឈ្មោះ [redacted] នាង [redacted] ណ្ណដា) ភេទប្រុស អាយុ៥០ឆ្នាំ, ឈ្មោះ [redacted] មន្នី ហៅ ថៃនី ភេទស្រី អាយុ៣២ឆ្នាំ, ឈ្មោះ [redacted] លីហៀង ហៅ ហៀង ភេទប្រុស អាយុ៣៤ឆ្នាំ, ឈ្មោះ [redacted] សាវី ហៅ បាក់ ភេទប្រុស កើតឆ្នាំ១៩៨០, ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៩ឆ្នាំ, ឈ្មោះ [redacted] សារ៉ែន ហៅ ម៉ាប់ ហៅ ខ្សែន ភេទប្រុស កើតឆ្នាំ១៩៩២ និងឈ្មោះ [redacted] ណារ៉ែន ភេទស្រី កើតឆ្នាំ ១៩៨៩ (អត្តសញ្ញាណខាងលើ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សំអាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៦ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៤០៤ និងមាត្រា៤០៦ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

ឃ. ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ គិត ភេទប្រុស កើតឆ្នាំ១៩៨២ (អ
សញ្ញាណខាងលើ) ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសម
ថែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច០១ នៃច្បាប់ស្តីពីការត្រួតពិនិ
គ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

៣៧. តាមលទ្ធផលកោសលវិច្ច័យគ្រឿងញៀនលេខ ៧៨៩៧/១៦ មពអជបគញ ចុះថ្ងៃ
១២ ខែធ្នូ ឆ្នាំ២០១៦ លើសំណាកសង្ស័យជាគ្រឿងញៀនរបស់ឈ្មោះ [redacted] រ៉ូហ្វា បង្ហាញថា វត្ថុមា
មានវត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណជាតុសុទ្ធគិតជាភាគរយ ៦៨.៩៨%។

៣៨. តាមលទ្ធផលកោសលវិច្ច័យគ្រឿងញៀនលេខ ៧៨៩៨/១៦ មពអជបគញ ចុះថ្ងៃ
១២ ខែធ្នូ ឆ្នាំ២០១៦ លើសំណាកសង្ស័យជាគ្រឿងញៀនរបស់ឈ្មោះ [redacted] ចំរើន បង្ហាញថា វត្ថុមា
មានវត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណជាតុសុទ្ធគិតជាភាគរយ ៧១.០៨%។

៣៩. វត្ថុតាងដែលដកហូតបានជាថ្នាំញៀនជាវត្ថុមានគ្រោះថ្នាក់ដល់សុខភាព គប្បីរឹបអូស។

៤០. សម្ភារមានដូចជាជញ្ជីងថ្លឹងគ្រឿងញៀន, រថយន្តម៉ាក តូយ៉ូតាកូរ៉ូឡា ឆ្នាំ១៩៩៤ ពណ៌
បៃតងចាស់, ទូរស័ព្ទដៃ, ម៉ាស៊ីនMP4, កូនថង់សម្រាប់ច្រកគ្រឿងញៀន និងសម្ភារសម្រាប់ជក់គ្រឿង
ញៀន ដូចមានក្នុងកំណត់ហេតុដែលសមត្ថកិច្ចដកហូតបានពីឈ្មោះ [redacted] មន្នី, ឈ្មោះ [redacted] សារ៉េន
ឈ្មោះ [redacted] សីហា, ឈ្មោះ [redacted] នាង និងឈ្មោះ [redacted] លីហៀង គឺជាវត្ថុដែលជនជាប់ចោទប្រើប្រាស់
ដើម្បីបំរើឲ្យការប្រព្រឹត្តបទល្មើស និងជាកម្មសិទ្ធិរបស់ជនជាប់ចោទ គប្បីរឹបអូស។

៤១. ជនជាប់ចោទឈ្មោះ [redacted] នាង និងឈ្មោះ [redacted] មុន្នី ពុំមានឯកសារ និងភស្តុតាងដើម្បី
បញ្ជាក់ឲ្យបានច្បាស់លាស់ពីការកើនឡើងនូវទ្រព្យរបស់ខ្លួនមានជាដី ថ្លៃចំណាយសាងសង់ផ្ទះ និង
បន្ទប់ជួល ដែលមានតម្លៃច្រើនសន្ធឹកសន្ធាប់ ដូច្នេះទ្រព្យដែលកើតឡើងដោយពុំមានប្រភពច្បាស់
លាស់ អាចឲ្យតុលាការជឿជាក់បានថាគឺជាទ្រព្យដែលបានពីអំពើល្មើសខាងលើ គប្បីរឹបអូស។

៤២. ជនជាប់ចោទទាំង១០នាក់ ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន
កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦។

៤៣. ជនជាប់ចោទឈ្មោះ [redacted] ណារ៉ែន ភេទស្រី កើតឆ្នាំ១៩៨៩ បានរត់គេចខ្លួនរហូតមក
ដល់ពេលបច្ចុប្បន្ន និងត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ២៤៨ ចុះថ្ងៃទី០៤ ខែ
តុលា ឆ្នាំ២០១៦ រួចហើយ គប្បីបញ្ជប់អានុភាពនៃដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ និង
ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] ណារ៉ែន តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤៤. សេចក្តីសន្និដ្ឋានបួងសុំរបស់តំណាងអយ្យការនាពេលសវនាការថា អង្គហេតុគោលគឺ
ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយមេក្លោងគឺឈ្មោះ [redacted] នាង ដែលសូម្បីតែជាប់ពន្ធ
នាគារហើយនៅអាចជួញដូរគ្រឿងញៀនបានទៀត ប្តូរទៅពន្ធនាគារខេត្តសៀមរាបជួញដូរទៀត ចាប់

បានទម្ងន់មួយគីឡូក្រាមៗ ដំបូងគឺចាប់បានឈ្មោះ [redacted] ចំរើន ដែលទិញពីឈ្មោះ ផេង កុសល ហើយ [redacted] កុសល ទិញពីឈ្មោះ [redacted] រ៉ូហ្សា ហើយឈ្មោះ [redacted] រ៉ូហ្សា មានទំនាក់ទំនងជាមួយឈ្មោះ [redacted] ទាង និងមានអ្នកដទៃទៀតដែលនៅធ្វើការជាមួយឈ្មោះ [redacted] ទាងៗបានឆ្លើយសារភាពពុំមានភស្តុតាងដោះបន្ទុកឡើយ មានតែភស្តុតាងដាក់បន្ទុកដូចជាចម្លើយរបស់ [redacted] រ៉ូហ្សាៗ មានភស្តុតាងដាក់បន្ទុកឈ្មោះ [redacted] ចំរើន ប្រើប្រាស់ និងជួញដូរ ជាមួយឈ្មោះ [redacted] កុសល ឯឈ្មោះ [redacted] រ៉ូហ្សា និង [redacted] សាវ៉ែន ពាក់ព័ន្ធផ្ទាល់ជាមួយឈ្មោះ [redacted] ទាង តាមរយៈការឲ្យយកថ្នាំទៅឲ្យម៉ូយ ចំណែកអ្នកផ្សេងសុំមិនធ្វើការកត់សំគាល់ទេ សុំក្រុមប្រឹក្សាធ្វើការផ្តន្ទាទោសឈ្មោះ [redacted] ចំរើន, [redacted] រ៉ូហ្សា, [redacted] កុសល ពីបទ ប្រើប្រាស់ និងជួញដូរ តាមមាត្រា៤៥ និងមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ ចំណុច១ ចំណែកឈ្មោះ [redacted] ទាង និងឈ្មោះ [redacted] សាវ៉ែន ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ ចំណុច១ ចំណែកអ្នកផ្សេងសុំក្រុមប្រឹក្សាពិចារណាលើវិមតិសង្ស័យ និងសុំពិចារណាលើការសហការណ៍ក្នុងការតាមចាប់អ្នកផ្សេងបន្តទៀត និងពិចារណាលើអនីតិជនផងៗ ចំណែកបទល្មើសសំអាតប្រាក់សុំពិចារណាៗ សេចក្តីសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវលើចំណុចមួយចំនួន គប្បីសម្រេចតាមការប្តឹងសុំលើចំណុចទាំងនោះៗ

៤៥. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] មុន្នី ទាពេលសវនាការថា កំណត់ហេតុ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ [redacted] រ៉ូហ្សា ឆ្លើយផ្ទុយនឹងសវនាការ ហើយ [redacted] លីហៀង ក៏បញ្ជាក់ផងដែរចំពោះចម្លើយកន្លងមកដែលដាក់ថា ឥវ៉ាន់គឺសំដៅលើសម្ភារគ្រឿងឈើ និងបញ្ជាក់ថាប្រាក់ធ្វើផ្ទះ គឺបានពីការលក់ផ្ទះនៅខ្មែរ ដែលបញ្ជាក់ស៊ីសង្វាក់គ្នានឹងកូនក្តីខ្លួន [redacted] មុន្នី ដែលថា ប្តីគាត់បេក់ដីផ្ទះនៅខ្មែរយកមកធ្វើផ្ទះជួល ទើបអយ្យការសួរដេញដោលច្រើនដងក៏នៅតែរក្សាចម្លើយដដែលៗ មួយទៀត [redacted] រ៉ូហ្សា ថាអ្នកយកគ្រឿងញៀនឲ្យរាល់ដងគឺពាក់ម៉ាស់ តែតាមចម្លើយ [redacted] សាវ៉ែន បញ្ជាក់ថាពេលយកឲ្យអត់ពាក់ម៉ាស់ទេ ដូច្នេះសុំឲ្យធ្វើការពិចារណាលើចម្លើយទាំងនេះៗ [redacted] រ៉ូហ្សា ថាជនជាប់ចោទមួយចំនួនគំរាមកំហែងមិនពិតទេ ព្រោះ [redacted] សាវី បញ្ជាក់ហើយថា អត់មានទេ ស៊ីសង្វាក់នឹងភស្តុតាងមួយដែលនៅបន្ទប់ឃុំខ្លួនស្រីផ្សេង ប្រុសផ្សេង មិនអាចគំរាមបានទេៗ ទ្រព្យគឺកើតមិនពាក់ព័ន្ធនឹងគ្រឿងញៀនទេ សុំឲ្យតុលាការសម្រេចលើកលែងកូនក្តីខ្លួន និងលុបដីការបស់ចៅក្រមស៊ើបសួរដែលបានសម្រេចរឹបអូសទ្រព្យកូនក្តីខ្លួន ដើម្បីកូនក្តីខ្លួនបានប្រើប្រាស់វិញៗ សេចក្តីសន្និដ្ឋាននេះមិនទាន់មានលក្ខណៈត្រឹមត្រូវគ្រប់ជ្រុងជ្រោយទេ គប្បីតុលាការពិចារណាតាមច្បាប់ៗ

៤៦. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទផ្សេងទៀត នាពេលសវនាការថាឈ្មោះ [redacted] ចំរើន បានទទួលស្គាល់តែអង្គហេតុប្រើប្រាស់ តែបដិសេធអង្គហេតុជួញដូរ ចំពោះចម្លើយដែលឆ្លើយថាធ្លាប់ជូនឈ្មោះ ផុន យកថ្នាំញៀនទៅឲ្យគេចំនួនប្រហែលជា២០ដង តែ

កូនក្តីខ្លួនបញ្ជាក់ហើយថា ជូនទៅគឺគេឲ្យជូនទៅទិញអីហូបប៉ុណ្ណោះ មួយទៀតត្រង់ថាកាន់ទៅខ្លួនឯ ប្អូនដង់គឺ [redacted] ចំរើន ប្រមូលលុយជាមួយមិត្តភក្តិទិញជក់ ហើយចម្លើយរបស់ជនជាប់ចោទផ្សេងទៀ ក៏មិនមានជាក់បន្ទុកដែរ ដូច្នេះសុំក្រុមប្រឹក្សាពិចារណាអង្គហេតុនេះដែលអាចទុកជាវិមតិសង្ស័យ ត បើមានការផ្តន្ទាទោសវិញ សុំឲ្យពិចារណាទៅលើស្ថានសម្រាលដែលអយ្យការបានស្នើសុំឲ្យស្រ តាមមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពិចារណាលើស្ថានភាពជាអនីតិជនផ ហើយជនជាប់ចោទផ្សេងទៀត និងឈ្មោះ [redacted] សារី មិនមានភស្តុតាងគ្រប់គ្រាន់សុំពិចារណា។ សេចក្ សន្និដ្ឋាននេះមានលក្ខណៈសមហេតុផលលើចំណុចមួយចំនួន តែមិនទាន់ត្រឹមត្រូវទាំងស្រុងនោះទេ គប្បីតុលាការពិចារណាតាមច្បាប់។

៤៧. ជនជាប់ចោទឈ្មោះ [redacted] ចំរើន, ឈ្មោះ [redacted] វ៉ូហ្វា និងឈ្មោះ [redacted] សាវ៉ែន បាន និយាយសំដីចុងក្រោយថា ស្នើសុំបន្ធូរបន្ថយទោស គប្បីយកមកពិចារណា។

៤៨. ជនជាប់ចោទឈ្មោះ [redacted] មន្នី បាននិយាយសំដីចុងក្រោយថា សុំតុលាការកុំបង្គុកដ និងផ្ទះរបស់ខ្លួន និងសុំលើកលែងចោទប្រកាន់ គប្បីយកមកពិចារណា។។

៤៩. ជនជាប់ចោទឈ្មោះ [redacted] លីហៀង, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] សារី និងឈ្មោះ [redacted] សីហា បាននិយាយសំដីចុងក្រោយថា សុំតុលាការជួយរកយុត្តិធម៌ផង គប្បីយកមកពិចារណា។

៥០. ជនជាប់ចោទឈ្មោះ [redacted] នាង ជាបុគ្គលសំខាន់ និងជាមេខ្លោងក្នុងការលួងលោម អូសទាញ និងបង្គាប់បញ្ជាអ្នកដទៃឲ្យប្រព្រឹត្តអំពើជួញដូរគ្រឿងញៀន និងសំអាតប្រាក់ គប្បីពិចារណាអំពីទោសរបស់ជនជាប់ចោទរូបនេះ អោយមានលក្ខណៈធ្ងន់ធ្ងរជាងជនជាប់ចោទដទៃទៀត។

## ហេតុដូច្នេះ សាលាដំបូងខេត្តបន្ទាយមានជ័យ
## វិនិច្ឆ័យសេចក្តី

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មុន្នី, ឈ្មោ [redacted] សាវ៉ែន, ឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] លីហៀង, ឈ្មោះ [redacted] វ៉ូហ្វា, ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] សីហា

កំបាំងមុខឈ្មោះ [redacted] នាង ឈ្មោះ [redacted] ណាវ៉ែន

១. ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក. ឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ០២ឆ្នាំ០៦ខែ ពីបទ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានថែង និងផ្តន្ទាទោសតាមមាត្រា៤០ ក៏ថា

ខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

ខ. ឈ្មោះ [redacted] រ៉ូហ្សា ហៅ ស៊ីណា ហៅ មុំ ភេទស្រី អាយុ២៤ឆ្នាំ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ០៦ខែ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានថែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ. ឈ្មោះ [redacted] នាង (ឈួន វណ្ណដា) ភេទប្រុស កើតឆ្នាំ១៩៨០ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង សំអាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានថែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៤០៤, មាត្រា៤០៦ នៃក្រមព្រហ្មទណ្ឌ។

ឃ. ឈ្មោះ [redacted] មន្នី ហៅ ថៃនី ភេទស្រី អាយុ៣២ឆ្នាំ (អត្តសញ្ញាណខាងលើ)

ង. ឈ្មោះ [redacted] លីហៀង ហៅ ហៀង ភេទប្រុស អាយុ៣៤ឆ្នាំ (អត្តសញ្ញាណខាងលើ)

ច. ឈ្មោះ [redacted] សារី ហៅ ប៉ាក់ ភេទប្រុស កើតឆ្នាំ១៩៨០ (អត្តសញ្ញាណខាងលើ)

ឆ. ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៩ឆ្នាំ (អត្តសញ្ញាណខាងលើ)

ជ. ឈ្មោះ [redacted] សារ៉ែន ហៅ ម៉ាប់ ហៅ ឡែន ភេទប្រុស កើតឆ្នាំ១៩៩២ (អត្តសញ្ញាណខាងលើ)

ឈ. ឈ្មោះ [redacted] ណារ៉ែន ភេទស្រី កើតឆ្នាំ១៩៨៩ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ **០៥ឆ្នាំ** ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង **សំអាតប្រាក់** ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានថែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៤០៤, មាត្រា៤០៦ នៃក្រមព្រហ្មទណ្ឌ។

ញ. ឈ្មោះ [redacted] បីហា ហៅ គិត ភេទប្រុស កើតឆ្នាំ១៩៨២ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី១៨ ខែ



Scanned with CamScanner

កញ្ញា ឆ្នាំ២០១៦ បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ
ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ។ 196

២. រឹបអូសទ្រព្យសម្បត្តិដី និងផ្ទះ ជាអគារបន្ទប់ជួលរបស់ឈ្មោះ [redacted] នាង និងឈ្មោះ [redacted] មន្ទី ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលបានបង្កកតាមដី បង្កកទ្រព្យសម្បត្តិលេខ ១៩០៣ពស.ព្រទ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើប សាលាដំបូងខេត្តបន្ទាយមានជ័យ។

៣. រឹបអូសនូវវត្ថុតាងជាថ្នាំញៀន ដូចក្នុងកំណត់ហេតុដែលដកហូតបានពីឈ្មោះ យ៉ា ចំ និងឈ្មោះ [redacted] ហ្វា។

៤. រឹបអូសនូវសម្ភាររួមមាន ជញ្ជីងថ្លឹងគ្រឿងញៀន, រថយន្ត ម៉ាកតូយ៉ូតាកូរ៉ូឡា ឆ្នាំ១៩៩ ពណ៌បៃតងចាស់, ទូរស័ព្ទដៃ, ម៉ាស៊ីនMP4, កូនថង់សម្រាប់ច្រកគ្រឿងញៀន និងសម្ភារសម្រាប់ជ គ្រឿងញៀន ដូចមានក្នុងកំណត់ហេតុដែលសមត្ថកិច្ចដកហូតបានពីឈ្មោះ [redacted] មន្ទី, ឈ្មោះ [redacted] សាវ៉ែន, ឈ្មោះ [redacted] ប៊ីហា, ឈ្មោះ [redacted] នាង និងឈ្មោះ [redacted] ប៊ីហៀង។

៥. បញ្ឈប់អានុភាពដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ២៤៨ ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ២០១៦ ព ឈ្មោះ [redacted] ណាវ៉ែន របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។

៦. បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ណាវ៉ែន ភេទស្រី កើតឆ្នាំ១៩៨៩ (អត្ត សញ្ញាណខាងលើ តាមមាត្រា៣៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៨ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

បានឃើញ
បន្ទាយមានជ័យ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
បន្ទាយមានជ័យ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨
**ក្រឡាបញ្ជី**



Scanned with CamScanner

ព្រះរាជាណាចក្រ កម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទឈ្មោះ [redacted] សាន ចៅ [redacted] វណ្ណារ៉ា ............ ភេទ ប ... អាយុ ៣៧ ឆ្នាំ
សញ្ជាតិ ខ្មែរ ...បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស)។
ជាប់ចោទពីបទ ជួញដូរ ដោយខុសច្បាប់ នូវសារធាតុញៀន ...
ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣ ខែ ០៤ ឆ្នាំ ២០១៤...

## សូមគោរពមក

ឯកឧត្តមប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ

សូមទានជ្រាប

កម្មវត្ថុៈ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខៈ ០៧ "ឧ" ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យគ្រង់សេចក្តីសម្រេច ទាំងស្រុង ..........

យោងៈ សំណុំរឿងព្រហ្មទណ្ឌលេខ ៧១៥ ......ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថាៈ ដោយសាខ្ញុំបាទកើតទុក្ខមិនសុខចិត្តចំពោះការសម្រេចក្តី របស់សាលាដំបូងខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១៥ បានដាក់ពន្ធនាគាំរខ្ញុំបាទ ដោយពុំបានប្រព្រឹត្ត ដូចការចោទប្រកាន់របស់លោក ព្រះរាជអាជ្ញានោះឡើយ ដែលធ្វើអោយប៉ះពាល់ដល់សិទ្ធ និង ផលប្រយោជន៍ ស្របច្បាប់របស់ខ្ញុំ បាទយ៉ាងធ្ងន់ធ្ងរ។

អាស្រ័យហេតុនេះសូមឯកឧត្តមប្រធានមេត្តាទទួលយកពាក្យបណ្តឹងរបស់ខ្ញុំបាទដើម្បីអោយសាលាឧទ្ធរណ៍ ជួយស្វែងរកយុត្តិធម៌ តាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមប្រធាន មេត្តាទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

លេខ ៣៤៥ ...............ម១ ព្រៃស,ថ្ងៃទី២០ ខែមករា ឆ្នាំ ២០១៥

*បញ្ជាក់*

ស្នាមមេដៃស្តាំនេះពិតជាស្នាមមេដៃរបស់
ឈ្មោះ [redacted] សាន ចៅ [redacted] វណ្ណារ៉ា ...ដែល
កំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ប្រាកដមែន។
ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៥

ប្រធានមណ្ឌល

ឧត្តមអគ្គានុរក្ស [redacted]

ស្នាមមេដៃស្តាំ

បានឃើញនិងបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៥
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

សាលាដំបូងខេត្តបន្ទាយមានជ័យ
ចូល
លេខ ១៩
ថ្ងៃ ១៧ ខែ មីនា ឆ្នាំ ២០១៥
ម៉ោង ២:០០ នាទី

ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទឈ្មោះ [redacted] សាន ... [redacted] ... ភេទ ប្រុស អាយុ ៣៧ ឆ្នាំ
សញ្ជាតិ ខ្មែរ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស)។
ជាប់ចោទពីបទ ...
ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣ ខែ ០៤ ឆ្នាំ ២០១៤

## សូមគោរពមក

ឯកឧត្តមប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ

សូមទានជ្រាប

កម្មវត្ថុ: សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ: ០៧ "ជ" ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យគ្រង់សេចក្តីសម្រេច ...
យោង: សំណុំរឿងព្រហ្មទណ្ឌលេខ ៧២១៤ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា:ដោយសាខ្ញុំបាទកើតទុក្ខមិនសុខចិត្តចំពោះការសម្រេចក្តី របស់សាលាដំបូងខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែ មករា ឆ្នាំ២០១៥បានដាក់ពន្ធនាគារខ្ញុំបាទ ដោយពុំបានប្រព្រឹត្ត ដូចការចោទប្រកាន់របស់លោក ព្រះរាជអាជ្ញានោះឡើយ ដែលធ្វើអោយប៉ះពាល់ដល់សិទ្ធ និង ផលប្រយោជន៍ ស្របច្បាប់របស់ខ្ញុំ បាទយ៉ាងធ្ងន់ធ្ងរ។

អាស្រ័យហេតុនេះសូមឯកឧត្តមប្រធានមេត្តាទទួលយកពាក្យបណ្តឹងរបស់ខ្ញុំបាទដើម្បីអោយសាលាឧទ្ធរណ៍ ជួយស្វែងរកយុត្តិធម៌ តាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមប្រធាន មេត្តាទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

លេខ ៣៤៥ ម១ ព្រៃស,ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥

បញ្ជាក់
ស្នាមមេដៃស្តាំនេះពិតជាស្នាមមេដៃរបស់
ឈ្មោះ [redacted] សាន ... [redacted] ... ដែល
កំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ប្រាកដមែន។
ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥

ប្រធានមណ្ឌល

ឧត្តមអគ្គានុរក្ស ៣ [redacted]

ស្នាមមេដៃស្តាំ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
... ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥

[redacted]

Scanned with CamScanner